# ឥទ្ធិពលរបស់សត្វមកលើ
# ជីវភាពមនុស្សខ្មែរ

តាំងពីយូរលង់ណាស់មកហើយ មនុស្សនិងសត្វតែងតែរស់នៅដោយផ្សារភ្ជាប់ជាមួយនឹងធម្មជាតិ ។ ម្ល៉ោះហើយ ទំនាក់ទំនងរវាងភាគីទាំងបីនេះ តែងតែជះឥទ្ធិពលដល់គ្នាទៅវិញទៅមក ។

រហូតមកដល់សព្វថ្ងៃនេះ វត្តមានសត្វនៅទីកន្លែងណា សម្រែកសត្វរាត្រីចរ មានប្រផ្នូលយ៉ាងណានោះ ក៏នៅតែមានមនុស្សខ្មែរជឿ និងយកចិត្តទុកដាក់ជាពិសេសនៅឡើយ ។ បន្ទាប់ទៅនេះ ខ្ញុំសូមលើកយកបាតុភូតមួយចំនួនមកបង្ហាញជូនដើម្បីជ្រាប និងទុកជាការយល់ដឹងខ្លះ ៗ អំពីជំនឿរបស់ខ្មែរ ពីបុរាណ ។

១/ សម្រែកខ្វែងស្រាក ខ្មែរយើងធ្លាប់ជឿថា ខ្វែងស្រាក មៀម លលកខ្មោច សុទ្ធសឹងជាអ្នកបំរើ ឬជាអ្នកនាំសាររបស់ខ្មោច ព្រាយ បិសាច ។ សម្រែកសត្វទាំងនេះនៅពេលយប់ ច្រើនតែធ្វើឲ្យមនុស្សម្នាក្មេងចាស់ ភ័យ ខ្លាចញ័ររន្ធត់ ។ គេធ្លាប់ចំណាំថា បើកាលណាខ្វែងស្រាកទំយំនៅលើដំបូលផ្ទះណា ឬក៏ទំនៅលើមែកឈើជិតផ្ទះណា មនុស្សក្នុងផ្ទះនោះនឹងឈឺធ្ងន់ ឬស្លាប់ផងក៏សឹងមាន ។

២/ សំឡេងសត្វឱឡុយំ ចាស់ៗ ធ្លាប់និយាយថា មានសត្វឱឡុ ពីរប្រភេទគឺ ឱឡុគោ និងឱឡុស្ទឹក ។

ឱឡុស្ទឹក ជាធម្មតាមានមាឌតូច ឯសម្រែករបស់វាក៏ពុំបណ្តាលឲ្យមានគ្រោះមហន្តរាយអ្វីដែរ ។ តែចំពោះឱឡុគោវិញ មានមាឌធំជាងត្មាត ជាងកេងកងទៅទៀត ។ វាយំឮសូរ (ម៉!!...) ដូចសំឡេងគោយំអញ្ចឹង ។ វាកម្រនឹងយំណាស់ ។ ពេលយប់ វាច្រើនតែយំនៅលើដើមឈើធំដែលដុះលើកំពូលភ្នំ ។ ដូចនេះហើយ សម្រែករបស់វាលាន់ឮទៅឆ្ងាយបន្តិវដែរ ។ កាលណាឮសម្រែករបស់វានៅពេលយប់ស្ងាត់ អ្នកផងតែងតែមានអារម្មណ៍ភ័យរន្ធត់ ព្រោះតាមឮចាស់ ៗ និយាយតៗ គ្នាមកថា បើសត្វឱឡុគោនេះយំបែរមុខឆ្ពោះទៅទិសណា ស្រុកភូមិនៅទីនោះច្បាស់ជាជួបគ្រោះវិបត្តិភ័យអន្តរាយ ដូចជា ជំងឺអំបល់ ស្លាប់រង្គះរង្គាលដូចយ៉ាងជំងឺអុតធំ ជំងឺអាសន្នរោគ ទុរ្ភិក្សអត់ឃ្លានជាដើម ។

៣/ ឈ្លូសចូលភូមិ ឈ្លូសជាសត្វព្រៃ ផ្ទាំងបំផុត ។ តាមចរិតធម្មជាតិរបស់វា វាខ្លាចមនុស្សខ្លាចស្រុកភូមិណាស់ ហើយមិនងាយនិងហ៊ានដើរមកកាន់ទីជិតៗ លំនៅរបស់មនុស្សឡើយ ។ ប៉ុន្តែដោយចៃដន្យ ប្រសិនបើវារត់ចូលមកក្នុងភូមិ ទោះរត់កាត់ទទឹងភូមិ ឬបណ្តោយភូមិក្តី ទោះរត់ឆ្លងផុតរួចខ្លួនក្តី ទោះត្រូវអ្នកស្រុកវាយសម្លាប់បានក្តី ចាស់បុរាណតែងតែទស្សន៍ទាយថា ស្រុកភូមិនោះនិងកើតមានវិបត្តិ ចលាចល ភ័យកិត ឬមានហេតុឧបទ្រពចង្រៃបែបណាមួយកើតឡើងជាមិនខាន ដូចជាឈ្លោះទាស់ទែង បែកបាក់សាមគ្គីគ្នា មានកិតភ័យត្រូវឃ្លាតចាកចោលស្រុក ភូមិ ឬមានកើតហេតុ

ចង្រៃផ្សេងៗ ទៀត ។

៤/ ព្រួត ឃ្មុំចូលផ្ទះ ព្រួតឃ្មុំ ជាបាណកសត្វ គ្រេបលំអងផ្កាធ្វើទឹកដែលមានរស់ជាតិផ្អែមស្អិតដូចស្ករ ។ ក្រៅពីផ្តល់ផ្ទិត ទឹកឲ្យមនុស្ស វាក៏មានចរិតអវិជ្ជាមានខ្លះ ៗ ដែរ ។ ចាស់ ៗ ខ្មែរមានជំនឿថា បើឃ្មុំចូលផ្ទះ និងនាំមកនូវលាភសក្ការៈដល់ម្ចាស់ផ្ទះ តែកុំបុករុករវា ។ ចំពោះសត្វព្រួតវិញ វាមិនមែនចូលមកនៅដោយកសាងជាផ្ទិត ជាក្បាលទឹកដូចឃ្មុំទេ គឺវាគ្រាន់តែហើរចូលផ្ទះមួយរយៈខ្លីហើយក៏ហើរចេញផុតទៅ ។ បើវាចូលផ្ទះណា ហើយមានទិចមនុស្ស សត្វក្នុងផ្ទះនោះ តាមទំនាយចាស់ ៗ ពីបុរាណថា នឹងមានឧបទ្រព្យចង្រៃ វិនាសទ្រព្យសម្បត្តិក្នុងផ្ទះនោះជាប្រាកដ មានកូនចៅក្នុងផ្ទះឈឺ ឬងាប់គោ ក្របីជាដើម ។

៥/ ក្រៀលយំ ក្រៀលជាសត្វស្លាបរកស៊ីតាមបឹងបួរ ថ្មុកត្រពាំង ។ វាមានសម្បុរខ្មៅ មាឌ ធំហើយខ្ពស់ ។ គេអាចយកស្លាបវាមកធ្វើជាផ្ចិតយ៉ាងធំ ។ បណ្តាជនខ្មែរធ្លាប់ពោលត ៗ គ្នាមកថា កាលណាគេឃើញសត្វក្រៀលមួយគូ ឬច្រើន ហើរយ៉ាងខ្ពស់ជារង្វង់មូល ហើយយំឮសូរ (ក្រូល ៗ...) បន្ទឺស្នូរយ៉ាងក្រលួចនោះ គេនាំគ្នាសន្មតថា នៅក្នុងស្រុកភូមិនាតំបន់នោះ និងមានគ្រមុំកំម្លោះពង្រត់គ្នា

៦/ សសេះយំ= (ប្រយាបតឿន) សត្វសសេះជាបក្សីរស់ក្នុងព្រៃឬក៏នៅជិតៗ លំនៅឋានរបស់មនុស្សផងដែរ ។ វាមានដុះរោមក្រញាំងនៅលើក្បាលដូចជាកំប៉ោយ ។ វាមានសម្បុរលឿងស្រអាប់ ។ វាស្វះស្វែងរកអាហារដោយចោះឈើពុក ដើម្បីចឹកស្រមោច ឬសត្វល្អិតផ្សេង ៗ ស៊ីជាអាហារ ។ វាចឹកយ៉ាងញាប់ទៅលើឈើពុក ឮសូរ (ត្រុល ៗ...) អ្នកស្រុកអ្នកភូមិនៅតំបន់ស្រុកគិរីវង្ស តែងតែនាំគ្នាចំណាំត ៗ គ្នាមកថា កាលណាគេឮវាយំ កិក ! កិក ! កិក ! បែបញាប់រន្ថិននោះ គេយល់ថានេះជាប្រផ្នូលល្អ ទំនាយទាយថា នឹងមានលាភអ្វីម្យ៉ាងមិនខាន ។ ជនណាដែលនៅជិតកន្លែងវាយំ (តឿន) ឮកិក ៗ ! នេះតែងតែបន្ទឺសំឡេងតបទៅវិញយ៉ាងខ្លាំង ៗ ថា "ប្រយាប ! មានលាភ ! " ។ គេថារបៀបនេះទាល់តែសសេះលែងយំទើបគេឈប់ថា ។ លុះវាយំកិក ៗ ! របៀបនេះអស់ចិត្តហើយ វាក៏ហើរទៅកាន់ទីផ្សេងបាត់ទៅ ។ យំរបៀបនេះ គេនិយមហៅថា "ប្រយាបតឿន"

៧/ ក្អែកបួលៈ ក្អែកជាបក្សីសម្បុរខ្មៅរលើប ។ សត្វនេះ រស់នៅមិនឆ្ងាយពីស្រុកភូមិទេ ព្រោះវាចូលចិត្តឆាប ឆក់ ពងមាន់ កូនមាន់ ឬត្រី សាច់ ដែលអ្នកស្រុក អ្នកភូមិហាលនៅតាមស្នូរក្បែរផ្ទះ ។ សត្វនេះមានចរិតឆ្អើល ខ្លាច ភ័យសស្ងើតសស្ងក់ ។ សត្វនេះថ្វីបើវាឆ្អើលខ្លាចមនុស្ស តែវារស់នៅមិនដាច់ឆ្ងាយពីមនុស្សទេ ។ ដូច្នេះហើយបានជាធ្លាប់មានរឿងដំណាលផ្សេង ៗ និយាយដល់រឿងក្អែកដូចជារឿងល្បើកលោកឡាហ្វុនតែន ដំណាលអំពី "ក្អែក និងកញ្ជ្រោង... " ចំរៀងខ្មែរបុរាណ មានចំណងជើងថា "បង្គងក្អែក" ដែលមានអត្ថន័យកំសត់ស្រងេះស្រងោច សឹងជាចំរៀងបកស្រាយអំពី

ទុក្ខចំបែងនៃការនិរាសបែកបាក់គ្នា ។ តាមជំនឿតៗ គ្នាមក កាលណាគេឮក្អែកបូល អកវ៉ូវៗ ! ឡូវ ៗ ! ក្រវ៉ាក ៗ ! គេតែជឿថា បងប្អូនគ្រួសារដែលឃ្លាតទៅឆ្ងាយនោះ និងវិល ត្រឡប់មកវិញ ។ ម្យ៉ាងទៀត បើវាបន្ទឺសូរថា អកវ៉ូវ ! អកវ៉ូវ ! អកវ៉ូវ ! ញាប់រន្ថើនដដែល ៗ ច្រើនដងនោះ គេជឿថាមានមនុស្សជាភ្ញៀវ ឬជាសាច់ញាតិមកដល់ភ្ញាម ៗ ឥឡូវនេះហើយ ។ ប៉ុន្តែ គួរឲ្យស្តាយពន់ពេកណាស់ បច្ចុប្បន្ននេះ ក្មេងៗ សាក្រោយមួយចំនួនពុំស្គាល់ក្អែកទាល់តែសោះ ព្រោះតាំងពីស្រុកយើងកើតមានសង្គ្រាម ក្អែកនៅស្រុកខ្មែរទាំងប៉ុន្មាន ត្រូវគេចខ្លួនហើរទៅបាត់អស់ ដើម្បីទៅរស់នៅទីតំបន់ណា ដែលមានសេចក្តីសុខស្ងប់ ។

៨/ កុកទមផ្ទះ ៖ នៅស្រុកខ្មែរយើងមានពូជកុកជាច្រើនប្រភេទ ដូចជាកុកគ្រោង កុកក្រសា កុកនទាល កុកស កុកសាប់ ។ល។ ប៉ុន្តែនៅទីនេះគេច្រើនសំដៅទៅលើកុកតែពីរប្រភេទទេ គឺកុកស និងកុកសាប់ ។ គេតែងតែកត់សម្គាល់ថា កាលណាកុកណាមួយ នៃប្រភេទកុកទាំងពីរ ទំលើដំបូលផ្ទះចាស់ៗ ប្រាប់ត ៗ គ្នាមកថា "ចង្រៃ" ខ្លាំងណាស់ ។ គេតែងចងក្រងជាពាក្យទំនៀមថា "...ចង្រៃដូចកុកទំផ្ទះ ដូចរន្ទះបាញ់ភូមិ..." បានន័យថា អព្ភូតហេតុទាំងពីរយ៉ាងនេះ ចង្រៃដូចគ្នា ។ ដូច្នេះ កាលណាមានហេតុបែបនេះកើតឡើង ខ្មែរ ៗ ដែលមានជំនឿ គេតែងតែនិមន្តព្រះសង្ឃមកចំរើនព្រះបរិត្តបណ្តេញឧបទ្រពចង្រៃ ឬក៏អញ្ជើញគ្រូមកបង្កក់ ប្រោះព្រំ កំចាត់នូវឧបទ្ទវហេតុនេះ ដើម្បីឲ្យម្ចាស់ផ្ទះរស់នៅក្នុងសុភមង្គលឡើងវិញ ។

៩/ ពស់ ឬថ្លាន់ចូលផ្ទះ សត្វលូនទាំងពីរបែបនេះ ជាធម្មតាមិនសូវចូលចិត្តនិងមនុស្សម្នា ឬមិនមែនដែលរស់នៅក្នុងផ្ទះមនុស្សទេ លើកលែងតែពស់សង់សឿ ដែលវាចូលមកលំនៅស្ថានមនុស្សម្តងម្កាល ដើម្បីចាប់កណ្តុរស៊ីជាអាហារ ។ ពស់ដែលគេធ្លាប់ឃើញចូលផ្ទះ ដោយចៃដន្យនោះ គឺពស់ព្រៃ និងពស់ថ្លាន់ ។ ពស់ទាំងពីរប្រភេទនេះ មានចរិតស្លូតបូត មិនសាហាវដូចពស់អសិរពិសផ្សេង ៗ ទៀតឡើយ ។ បើកាលណាវាចូលមកនៅលើផ្ទះ ក្រោមផ្ទះនោះ ចាស់ពីបុរាណកំណត់ថាវាមកឲ្យសុខសប្បាយទេ មិនបង្កនូវភ័យអន្តរាយបែបណាមួយឡើយ ។ កាលណាឃើញវាចូលមក គេត្រូវចាប់វាថ្នម ៗ ហើយបបោសអង្អែលលាបប្រេង លាបម្សៅរួចដុតធូប និយាយដូចនេះថា "ឯងចូលមកផ្ទះយើងនេះ សូមឯងនាំយកមកនូវលាភជ័យ សេចក្តីសុខ សេចក្តីចំរើន សុភមង្គលដល់យើង យើងលែងឯងឲ្យមានសេរីភាព ចូរឯងទៅរស់នៅក្នុងព្រៃឲ្យបានសេចក្តីសុខចុះ" ។

១០/ អំពិលអំពែកចូលផ្ទះ អំពិលអំពែកជាសត្វដង្កូវម្យ៉ាង មានជាតិហ្វូសហ្វ័រភ្លឺភ្លិបភ្លែត ៗ នៅត្រង់ពោះរបស់វា ។ នៅពេលយប់ ជាពិសេសនៅរដូវវស្សាដែលមានភ្លៀងធ្លាក់ជោគជាំ អំពិលអំពែកកើតកូនកើតចៅជាច្រើន ។ លុះពេលព្រលប់មកដល់ វាហើរ ព្រោងព្រាតបញ្ចេញពន្លឺភ្លិបភ្លែត ៗ

ពាសពេញព្រៃ ឬពាសពេញភូមិ ។ សត្វអំពិលអំពែកចូលចិត្តហើរលេងសប្បាយតាមវាលស្មៅ នៅទីធ្លាក្បែរផ្ទះក្នុងភូមិ ។ ប្រការដែលគួរឲ្យកត់សំគាល់ គឺវាកម្រនឹងហើរចូលមកក្នុងផ្ទះណាស់ ។ ប៉ុន្តែ ជាចៃដន្យបើវាហើរចូលក្នុងផ្ទះ ទោះបីលើ ឬក្រោមផ្ទះក្តី ចាស់បុរាណទាយថាវានាំយកលាភសក្ការៈមកឲ្យម្ចាស់ផ្ទះនោះ ។ ជួនកាលអំពិលអំពែកនៅហើរវិរក់ឆ្វែលចុះឆ្វែលឡើងក្នុងផ្ទះអស់ពេលយ៉ាងយូរ ។ ជួនកាលវាចូលមកតែមួយភ្លែតក៏ចេញទៅវិញ ។ យោលទៅតាមបាតុភូតបែបនេះ ទំនាយក៏ទាយទៅតាមនោះដែរគឺថា បើវាចូលមកហើរចុះ ហើរឡើងអស់រយៈពេលយូរ គេជឿថានិងមានលាភធំណាស់ ។ តែបើចូលមកតែមួយភ្លែត ហើរចេញបាត់ទៅវិញ ទំនាយទាយថា មានលាភដែរ តែបានបន្តិចបន្តួចប៉ុណ្ណោះ ។ អ្នកភូមិខ្លះ ៗ នៃខេត្តកំពង់ធំ កាលបើឃើញអំពិលអំពែកហើរចូលផ្ទះ គេហាមកូនហាមចៅមិនឲ្យចាប់វាលេងឡើយ ព្រោះគេជឿថា បើកាលណាវាងាប់ដោយក្មេងចាប់ដៃធ្ងន់ពេកនោះ នឹងនាំឲ្យមានគ្រោះមហន្តរាយវិញ ។ គេបង្គាប់កូនចៅឲ្យសូត្រជាបទស្មើ ៗ ថា "អំពិលអំពែកអើយកុំទៅផ្ទះគេ គេចាប់គេចង មកផ្ទះហបង បងឲ្យកងពាក់ បាក់មួយទៅ បងឲ្យមួយទៀត ..." យ៉ាងនេះជាដើម ។

១១/ តុកកែយំៈ តុកកែជាសត្វមួយប្រភេទ ដែលរស់នៅតាមដើមឈើឬក្នុងលំនៅឋានរបស់មនុស្ស ត្រាច់ចរតាមសសរ តាមផ្ទាន ផ្ទោង ដើម្បីស្វែងរកចាប់ចំណីស៊ីជាអាហារ ។ វាក៏ពងហើយភ្ញាស់កូនបន្តពូជពង្សនៅទីនោះផងដែរ ។ ចាស់ ៗ ធ្លាប់ប្រាប់ត ៗ គ្នាមកថា បើតុកកែណាយំតិចជាង ៧ ម៉ាត់ នោះពុំល្អឡើយព្រោះវាបកស្រាយនូវឋានមពលខ្សោតយ (រាសីដាក់, វាសនាតិច) ដែលចាស់ ៗ ប្រាប់ឲ្យដេញវាចេញពីផ្ទះ ។ បើតុកកែ ណាដែលយំចាប់ពីប្រាំពីរម៉ាត់ រហូតទៅដល់ ១៥ ឬ ១៨ ម៉ាត់នោះ លោកទាយថា ល្អពន់ពេកណាស់ គួរលៃថែរក្សាវាឲ្យនៅជាប្រចាំនៅក្នុងផ្ទះ ព្រោះតាមរយៈចំនួនម៉ាត់ដែលវាយំបានច្រើនយ៉ាងនេះ វាជាការបកស្រាយនូវឋាមពលខ្លាំងក្លា (រាសីខ្ពស់ ជោគជតាល្អវិសេស) ។

១២/ អំពីព្រាបចូល ឬព្រាបចេញៈ ព្រាបជាសត្វព្រៃ មានចរិតស្លូតបូត ហើយគេងាយនិងផ្សាំងវាណាស់ ។ ក្នុងករណីទូទៅ វាហាក់សំដែងការស្និទ្ធស្នាលជាមួយមនុស្ស រូបរាងល្អល្អះគួរឲ្យស្រឡាញ់ណាស់ ។ សំឡេងយំរបស់វាឮសូរដូចសំឡេងថ្ងូររបស់អ្នកជំងឺ សមដូចពាក្យទំនៀមលោកពោលថា "ថ្ងូរដូចព្រាប" ម្យ៉ាងទៀតមានពាក្យអ្នកស្រុកធ្លាប់ចំអន់លេងថា "ព្រាបណាពូកែថ្ងូរព្រាបនោះពិតជាធាត់" ។ ចាស់ៗ ធ្លាប់ចំណាំថា បើកាលណាគេឃើញសត្វព្រាបហើរទាំងហ្វូងមកអាស្រ័យនៅលើផ្ទះណា នោះជាសញ្ញាប្រាប់ឲ្យដឹងថា គ្រួសារនោះនឹងមានជោគជតារាសីល្អ គួរថែរក្សាការពារនោះឲ្យវារស់នៅជារៀងរហូតតទៅ វាពិតជាបានល្អ ត្រដាក់ត្រជុំមិនខាន ។ ផ្ទុយទៅវិញ បើកំពុង

តែរស់នៅលើផ្ទះណាមួយសុខៗ ស្រាប់តែនាំគ្នាហើរចេញពីផ្ទះលែងនៅតទៅទៀត នោះជាសញ្ញាប្រាប់ឲ្យដឹងថា រាសីម្ចាស់ផ្ទះនឹងធ្លាក់ចុះ និងមានហេតុភេទមិនល្អតទៅថ្ងៃមុខ ។

១៣/ វត្តមានសត្វចាបដូនតា: សត្វបក្សីដែលមានមាឌតូចជាងចាបធម្មតានេះ ជាសត្វមានចរិតរពិសពន់ពេកណាស់ ។ បើវាទំនៅលើមែកឈើណានោះ វាមិនដែលនៅស្ងៀមបានមួយភ្លែតឡើយ វាលោតចុះលោតឡើង ហើយយំឮសូរចាច់ ៗ ! ។ ជាធម្មតា វាចូលចិត្តរស់នៅលើដើមឈើជិត ៗ ផ្ទះមនុស្ស ហើយហក់ចុះ ហក់ឡើង យំចាច់ ៗ ឥតឈប់ឈរ ។ សត្វនេះ មានវត្តមានតាមពេលតាមកាល (Oiseau passager) ពោលគឺមិនមែនរស់នៅជាអចិន្ត្រៃយ៍ដូចអស់សត្វបក្សាបក្សីផ្សេងឯទតឡើយ ។ ខ្មែរយើងធ្លាប់ជឿត ៗ គ្នាតាំងពីរយូរមកហើយថា: សត្វចាបដូនតានេះ ចាតំណាងព្រលឹងដូនតាខ្មែរទាំងអស់ មានទីស្នាក់អាស្រ័យនៅជាអចិន្ត្រៃយ៍នៅឯព្រៃហេមពាន្តឯណោះ ។ តែកាលណាចូលដល់ជិតពាក់កណ្តាលខែភទ្របទហើយនោះ សត្វចាបដូនតាបានធ្វើដំណើរពីព្រៃហេមពាន្តមកដល់ប្រទេសខ្មែរ ។ ត្រង់នេះស្របនឹងជំនឿខ្មែរថា នៅវស្សានរដូវ ពេលដែលមេឃមានពពកខ្មៅមីដេរដាស មានភ្លៀងធ្លាក់ជោគជាំទាំងយប់ថ្ងៃឥតស្រាក មានផ្គរលាន់ឮសូរគគ្រឹមឮដ៏អាកាសនោះ ស្តេចយមបាលបានបើកលែងព្រលឹងខ្មោចដូនតាដែលមានទោសជាប់នៅឯស្ថានិនរកនោះ ឲ្យមករកកូនចៅដើម្បីបានទទួលអាហារភោជន ដែលកូនចៅតែងនាំគ្នាទៅធ្វើបុណ្យបញ្ជូនកុសលនៅតាមវត្តអារាមនានា ។ តាមចំណាំ សត្វចាបដូនតាមកកាន់ស្រុកខ្មែរយើងក្នុងកាលវេលាមួយទៀងទាត់ណាស់ គឺចូលដល់ជិតពាក់កណ្តាលខែភទ្របទមកដល់ លុះចប់រដូវភ្ជុំបិណ្ឌ ហើយក៏ស្រាប់តែទៅបាត់អស់គួរឲ្យកត់សំគាល់ពន់ពេកណាស់ ។ ចាស់ ៗ ធ្លាប់និទានថា លុះផុតរដូវភ្ជុំបិណ្ឌហើយ សត្វចាបដូនតាដែលជាតំណាង ព្រលឹងដូនតា បានលាយើងជាកូនចៅ វិលត្រឡប់ទៅលំនៅឋានឯព្រៃហេមពាន្តវិញ ។ លុះដល់ខែភទ្របទ រដូវភ្ជុំបិណ្ឌឆ្នាំក្រោយ ទើបមកម្តងទៀត ។

១៤/ ឆ្មា ឆ្កែ ចូលផ្ទះ◌: សត្វទាំងពីរប្រភេទនេះ សុទ្ធសឹងតែជាសត្វស្រុក ។ ជួនកាល ពួកវាមានម្ចាស់គ្រប់គ្រងថែរក្សា ។ ជួនកាលវាក៏ត្រាច់ចរ ម្តងទៅត្រង់នេះ ម្តងទៅត្រង់នោះ ឥតទីដៅច្បាស់លាស់ឡើយ ។ មានជួនកាលទៀតពួកវាដែលរស់នៅក្រោមដំបូលផ្ទះណាមួយ ហើយដោយមានហេ◌តុបច្ច័យជាអាថ៌កំបាំងក្តី ដោយត្រូវម្ចាស់វាយធ្វើបាបបង្អត់អាហារក្តី វាក៏សំរេចចិត្តចេញពីផ្ទះនោះដើម្បីធ្វើការផ្សងព្រេងទៅរកទីថ្មីទៀត ។ ចំពោះសត្វអស់នេះ ចាស់ ៗ ធ្លាប់មានពាក្យស្មោកខ្វះ ៗ ដែរ ដូចជាពោលថា "ពុតសិស្សគ្រូបី ពុតស្រីប្តីលែង ពុតគោជ្រលែង ពុតឆ្កែបង់ម្ចាស់[1] " ។ ឯ ពាក្យស្មោក

---

[1]- មនុស្សឬសត្វទាំងបួនជំពូកនេះ ចាស់ ៗ លោកចាត់ថា ចង្រៃណាស់ មិនគួរឲ្យសេពគប់ឡើយ ។

- គោជ្រលែង: គោគេចវេះដើរចោលហ្វូង ឬមិនចង់ចូលផ្ទះដូចសត្វដទៃទៀត ។

មួយឃ្លាទៀតនោះ ពាក់ព័ន្ធដល់សត្វឆ្មា "ឆ្មាសម្បុរបី ស្រីគ្រប់លក្ខណ៍" ពាក្យស្លោកខាងក្រោមនេះមានអត្ថន័យល្អ ។ ចាស់ ៗ តែងតែមានជំនឿត ៗ គ្នាមកថា កាលណាឆ្មា ឬឆ្កែ ចូលមកនៅក្នុហផ្ទះយើងនោះ ចាត់ទុកជាប្រផ្នូលល្អណាស់ ។ គេសន្មតថា ប្រហែលជាអានុភាពជាអាថ៌កំបាំងអ្វីបណ្ដាលចិត្តឲ្យសត្វទាំងនេះចូលមកនៅក្នុងផ្ទះយើង ក្នុងន័យនាំយកទ្រព្យសម្បត្តិលាភជ័យល្អមកឲ្យយើង ។ អាចគិតថា ប្រហ៨ែលជាផ្ទះនោះ ជាទីត្រជាក់ត្រជុំសុខក្សេមក្សាន្តហើយបានជាសត្វទាំងនេះសុំមកជ្រកកោននៅជាមួយ ដើម្បីសុំសេចក្ដីសុខ ។ ដូច្នេះ កាលបើមានហេតុភេទបែបនេះ ទោះបីយើងមានឆ្កែឆ្មាក្នុងសេចក្ដីសុខ ។ ដូច្នេះ កាលបើមានហេតុភេទបែបនេះ ទោះបីយើងមានបឆ្កែឆ្មាក្នុងផ្ទះយើងស្រាប់ហើយក្ដី គួរកុំធុញទ្រាន់ទើសទាល់ គួរទទួលវាឲ្យនៅផងចុះ កាលបើឃើញវាចូលមកនៅដោយមានអាកប្បកិរិយាស្លូតបូត ឱនលំទោន សុភាពរាបសាត ។ តទៅថ្ងៃមុខអ្នកច្បាស់ជាបានជួបវាសនាល្អជាមិនខាន ។ ធម្មតាសត្វឆ្កែឆ្មាក៏តែងមានពីរសណ្ឋានជាដារប គឺខ្លះល្អ ខ្លះទៀតអាក្រក់ ។ ឆ្មាសូម្បីវាមានសម្បុរបីក៏ដោយ ក៏មានអាក្រក់ដែរ ។ ប៉ុន្តែ ជួនកាលខ្លះ ពួកវាមិនមានចរិតអាក្រក់មក ពីកំណើតនោះទេ ប៉ុន្តែ ជួនកាលខ្លះ ពួកវាមិនមានចរិតអាក្រក់មកពីកំណើតនោះទេ ប៉ុន្តែចំណុះទៅនិងការអប់រំបង្ហាត់បង្រៀនរបស់ម្ចាស់វា ។ ចាស់ៗ ធ្លាប់ពោលថា ឆ្មាវាបន់ឲ្យតែម្ចាស់មាននឹងបានដេកពូក ។ ឯសត្វឆ្កែបន់ឲ្យតែម្ចាស់ងាប់ និងបានស៊ីចំណី ពោរពាសក្នុងពេលគេធ្វើបុណ្យឲ្យខ្មោចម្ចាស់វា ។

១៥/ ឆ្កែលូនៅពេលយប់ស្ងាត់: តាមធម្មតា ឆ្កែវាតែងព្រុះមនុស្សចម្លែក ព្រុះដេញសត្វឆ្កែផងគ្នាដែលវាពុំធ្លាប់ឃើញ ។ ប៉ុន៩តែ គេកម្រឮវាលូ ណាស់លើកលែងតែស្ថិតក្នុងករណី ដែលត្រូវម្ចាស់វាយកទៅប្រោសចោល (បំបរបង់) រកផ្លូវវិលមកផ្ទះវិញមិនឃើញប៉ុណ្ណោះ ហើយឆ្កែប្រភេទនេះលូតែ ពេលថ្ងៃទេ ។ ប៉ុន្តែ ប្រសិនបើនៅពេលយប់ស្ងាត់ គេឮវាលូយ៉ាងវែង បន្លឺសូរគ្រលួចបែបលន្លង់លន្លោច សូរគួរឲ្យ ព្រឺក្បាល គឺលូបញ្ចេញសំឡេងបែបនេះហើយដែល ចាស់ៗ ខ្មែរយើងកំណត់ថា ជាប្រផ្នូលមិនល្អសំរាប់ស្រុកភូមិទៅថ្ងៃមុខ ។ ចាស់តែងតែជឿថា ស្រុកទេសយើងមានចម្បាំងរាំងជល់ ទុរ្ភិក្សអត់ឃ្លាន ឬមានជំងឺរាតត្បាត ។

១៦/ គោក្រយៅក្រឡាច់: ជាទូទៅ គោជាសត្វមានផលប្រយោជន៍ចំពោះមនុស្ស ដោយផ្ដល់នូវកំលាំងអូសទាញ ផ្ដល់សាច់ជាអាហារ ផ្ដល់ទឹកដោះ និងផ្ដល់កូនសំរាប់បន្តពូជពង្ស ។ ខ្មែរយើងចំណាំដឹងថា គោទាំងអស់ពុំមានលក្ខណៈដូចៗ គ្នាទាំងអស់ទេ ។ ពួកខ្លះមានលក្ខណៈល្អ ដែលគេ

---

- ពុតសិស្សគ្រូបី: រៀនហើយរត់រកគ្រូថ្មីទៀត ញយ ៗ មានន័យថាចិត្តសាវា ។
- ពុតឆ្កែបង់ម្ចាស់: គឺឆ្កែរត់ចោលម្ចាស់ឥតហេតុផល ។

ជឿថា បើវាមិនចំរុងចំរើន យ៉ាងហោចណាស់ក៏វាមិនឲ្យទោសដល់ម្ចាស់ដែរ ។ ឯមួយ ពួកទៀត វាមានលក្ខណៈខុសប្លែកពីប្រក្រតី ។ គេមើលដឹងលក្ខណៈល្អ អាក្រក់នេះដោយសារក្រយៅរបស់វា ។ ក្រយៅដែលអាក្រក់នោះ គឺក្រយៅក្រឡាប់ ក្រយៅឈ្វាកក្រោល ក្រយៅរំកាយខ្ចាត់ ក្រយៅធាក់លាញ ។ល។ គោណាដែលមានក្រយៅមានភិនភាគដូចពោលមកនេះ គេចាត់ទុកជាសត្វចង្រៃ គេរិះរកគ្រប់វិធីដើម្បីលក់ ឬដូរចេញឲ្យផុតពីផ្ទះ ។ បើកាលណានៅតែរឹងរូសប្រើប្រាស់ ឬចិញ្ចឹមគោប្រភេទនេះ គេជឿថា នឹងមានហេតុអន្តរាយ វិនាសទ្រព្យសម្បត្តិ ឬមនុស្សក្នុងគ្រួសារឈឺថ្កាត់ ស្លាប់ព្រាត់ប្រាសក៏សឹងមាន ។ អំពីលក្ខណៈចង្រៃបែបនេះ ខ្មែរយើងធ្លាប់មានពាក្យស្លោកពោលថា "អំពិលឯត្បូង អណ្ដូងឯលិច គោក្រយៅក្រឡាប់ ប្រពន្ធដោះញ" ។ មានន័យថាបើមានដើមអំពិលនៅពីខាងត្បូងផ្ទះ បើមានអណ្ដូងនៅខាងលិចផ្ទះ បើមានគោក្រយៅក្រឡាប់ បើមានប្រពន្ធដោះញ នោះបុរាណាចារ្យលោកចំណាំថា ចង្រៃពន់ពេកណាស់ ។

១៧/ ត្រដេវរ៉ិចចាស់: ត្រដេវរ៉ិចជាបក្សីដែលរកស៊ីដោយមិនសូវបង្ហាញខ្លួនឲ្យមនុស្សម្នាឃើញងាយ ៗ នោះឡើយ ។ វាយំឮសូរ តេ ៗ រ៉ិច ! ៗ... យំផងហើរផង ហាក់ដូចជាភិតភិយណាស់ ។ ចំពោះសត្វត្រដេវរ៉ិចនេះ ចាស់ៗ ខ្មែរធ្លាប់និយាយជាពាក្យទំនឹមទំនៀមថា "ដេកយកជើងទ្រមេឃ ដូចសត្វត្រដេវរ៉ិច" មានន័យថា ជាមនុស្សប្រយ័ត្នប្រយែង មានការភ័យបារម្ភច្រើន ។ តែចំពោះចាស់បុរាណគាត់ធ្លាប់ចំណាំត ៗ គ្នាមកថា បើនៅពេលយប់ស្ងាត់ មានសត្វត្រដេវរ៉ិចចាល់ទាំងហ្វូងឮសូរ តេ ៗ រ៉ិច ៗ ... ទ្រហឹងអឹងអាប់ នោះច្បាស់ជាមានពពួកចោរមកលួចប្លន់នៅភូមិណាមួយក្នុងតំបន់នោះហើយ គេត្រូវនាំគ្នាប្រុងប្រយ័ត្នឡើង ។

១៨/ សត្វជើងបី: តាមធម្មតា សត្វពាហនៈជាចតុប្បាទ ដូចជាគោ ក្របី សេះ ដំរី ជ្រូក ឆ្កែ ឆ្មា ជាដើម តែងតែមានជើងបួនជាដរាប ។ ដូច្នេះ បើគេនាំគ្នាកំនត់ថា សត្វជើងបីនោះ តើគេសំគាល់ត្រង់លក្ខណៈបែបណាទៅវិញ ? ។ គេសំគាល់ថា សត្វជើងបី ចំពោះតែសត្វដែលជើងទាំងបួនរបស់វាមានសម្បុរមិនដូចគ្នា ។ ឧទាហរណ៍ ជើងបីសម្បុរខ្មៅ ជើងមួយសម្បុរស ឬផ្ទុយមកវិញ ជើងបីសម្បុរស ជើងមួយសម្បុរខ្មៅ នេះគេចាត់ថា សត្វនោះមានជើងបីហើយ ។ បើសត្វដែលគេចិញ្ចឹមណា ដែលមានលក្ខណៈដូចពោលខាងលើនេះ គេមិនចិញ្ចឹមទេ គេចាត់ទុកថាជាសត្វចង្រៃនាំមកនូវទុក្ខទោសឧបទ្រពចង្រៃដល់ម្ចាស់ជាមិនខាន ។

១៩/ កូនក្របីឃ្មៀច: តាមពូជរបស់វា ក្របីមានពីរពណ៌គឺសម្បុរខ្មៅនិងសម្បុរឃ្មៀច (ពណ៌កុលាប) ។ តាមការសង្កេត គេឃើញមានក្របីឃ្មៀចតិចបំផុត ។ កសិករខ្មែរមិននិយមចិញ្ចឹមក្របីឃ្មៀចទេ គេថាវាចាញ់កំដៅថ្ងៃជាងក្របីខ្មៅ ។ ចំពោះអ្នកដែលចិញ្ចឹមក្របីខ្មៅទាំងហ្វូង ៗ ឲ្យដេករួម

គ្នានៅក្នុងក្រោលតែមួយនោះ បើកាលណាហើយមានបាតុភូតចម្លែកមួយ គឺឃើញមេក្របីខ្មៅ ណាមួយកើតកូនមកជាឃ្មៀច នោះគេជឿថាជាបុព្វនិមិត្តប្រាប់ឲ្យដឹងអំពីការស្លាប់រង្គាល នៃហ្វូងក្របីឃ្មៀច នោះគេជឿថាជាបុព្វនិមិត្តប្រាប់ឲ្យដឹងអំពីការស្លាប់រង្គាល នៃហ្វូងក្របីដោយសារជំងឺអំបល់ ។

២០/ មនុស្សមានគភ៌មិនអាចជិះដំរីបាន: ដូចសត្វពាហនៈដទៃទៀតដែរ វាតែងតែមានការពាក់ព័ន្ធទៅនិងជីវភាពមនុស្សដែលយើងសូមលើកយកមកពណ៌នាដូចតទៅ ហ្មដំរីទាំងឡាយតែងតែមានការប្រយ័ត្នប្រយែង មិនអនុញ្ញាតឲ្យមនុស្សមានគភ៌ (ផើម) ជិះលើខ្នងដំរីឡើយ ។ បើគេនៅតែបំពារបំពានទៅលើតំណមនោះ ដំរីនិងរលាស់ជម្រុះមនុស្សផើមនោះឲ្យធ្លាក់ពីលើខ្នងវា ។

២១/ ហាមសាសងស្នេហានៅលើខ្នងដំរី ដោយឡែកពីតំណមមិនឲ្យមនុស្សផើមជិះលើខ្នងការសាសងតាមផ្លូវស្នេហាប្រឡូកប្រឡែងគ្នានៅលើខ្នងដំរីក៏ជាប្រការមួយពុំអាចអនុញ្ញាតបានដែរ ។ យើងពល់គ្នាដែលធ្លាប់ដឹងអំពីប្រពៃណីនេះ រួមទាំងហ្មដំរីផង នៅពុំទាន់បានស្រាវជ្រាវរកឃើញអំពីមូលហេតុច្បាស់លាស់នៅឡើយ ។ រហូតមកទល់ ពេលនេះ យើងគ្រាន់តែដឹងតាមរយៈចាស់ ៗ និយាយថា បើកាលណាគេនៅតែបំពារបំពានទៅលើតំណមនេះ ដំរីនិងស្រុត (ស្លាប់) ដោយពុំអាចព្យាបាលឲ្យជាបានឡើយ ។

២២/ ដំរីចូលរួមចំណែកក្នុងការនាំមកនូវភាពត្រជាក់ត្រជុំ នឹងព្យាបាលក្មេងអារ៉ឹះ ក្មេងអារ៉ឹះជាប្រភេទក្មេងដែល ពិបាកចិញ្ចឹម ព្រោះវាមានជំងឺពុំរ៉ៃជាប្រចាំ គឺជំងឺចំរុះច្រើនមុខ ឈឺនេះផង ឈឺនោះផង ពិបាកព្យាបាលជាទីបំផុត ។ ហេតុគយរឲ្យចម្លែក នៅត្រង់វាស្គមរីងរៃ ឈឺឥតមានថ្ងៃស្រាកស្រាន្តតែវាមិនស្លាប់ ។ ចាស់បុរាណធ្លាប់ព្យាបាលក្មេងអារ៉ឹះនេះតាមវិធីប្លែកៗ ជាច្រើន មានដាក់វាឲ្យអង្គុយក្នុងឈ្នាង ហើយយកទៅធ្វើពិធីឧបកិច្ចនៅត្រង់ផ្លូវបំបែកជាបួន ដាក់វានៅចំផ្លូវព្រះសង្ឃនិមន្តបិណ្ឌបាត ដើម្បីឲ្យព្រះសង្ឃទស្សន៍ ឬក៏យកទៅប្រគេនលោកធុតង្គឲ្យលោកព្យាបាល ឬក៏ឧបកិច្ចធ្វើជាឲ្យទៅលោកអាចារ្យចិញ្ចឹមជានិមិត្តរូប រួចទៅលោះយកមកវិញ ។ល។ និង ។ល។ តែនៅពេលនោះយើងសូមលើកយកវិធីមួយមកពណ៌នានោះគឺ ការព្យាបាលដោយមានអន្តរាគមន៍ពីដំរី ។ តាំងពីបុរមបុរាណរៀងដរាបមក ខ្មែរយើងតែងតែចាត់ទុកដំរីជាសត្វត្រជាក់ត្រជុំ ជាសត្វនាំមកនូវសុកមង្គល ជាសត្វតំណាងឲ្យទឹក និងភាពសំបូររុងរឿង ។ ជំនឿនេះបានចាក់ឫសយ៉ាងជ្រៅទៅក្នុងអារម្មណ៍ខ្មែរ រហូតដល់នាំ គ្នាជឿត ៗ មកថា បើកាលណាយល់សប្តឃើញដំរីនោះ ច្បាស់ជាមានភ្ញៀវជាមិនខាន ។ ខ្មែរខ្លះជឿថា ដំរីនាំមកនូវជោគវាសនាល្អ ធ្វើអ្វី ៗ តែងតែកើតចំរើនផលកាក់កបជានិច្ច ។ ដូច្នេះហើយបានជាស្រី ៗ នៅស្រុកស្រែខ្លះដែលចង់ចិញ្ចឹមនាងឲ្យបានផលចំរើន គេតែងទៅនិយាយអង្វរហ្មដំរីឲ្យជួយគេឲ្យបានស្ទាបបបូរមាត់ក្រោមរបស់ដំរី ។ ជួនកាលគេយកស្បែកដំរី

(ដែលងាប់) មកធ្វើជាជ្រញ់ហាន់ស្ងួកមកឲ្យដង្កូវនាងស៊ី ដើម្បីឲ្យលទ្ធផលល្អក្នុងការចិញ្ចឹម ។ ខ្មែរភាគច្រើនពិសេសគ្រួសារអ្នកមាន ច្រើនតែយកភ្លុកដំរីទាំង គូរមកដាក់តាំងលើតុកិត្តយស ឬលើខ្នងទូទុកជាគ្រឿងលំអផ្ទះផង និងទុកជាទ្រព្យត្រដាក់នៅក្នុងផ្ទះផង ។

ចំពោះក្មេងអារ៉ឹះ គេយកវាទៅដាក់ពីក្រោមពោះដំរី ឬដាក់ពីក្រោមមាត់ដំរី យកប្រមោយវាឲ្យស្ទាបក្បាលក្មេងនោះ ឬក៏ឲ្យវាព្រួសទឹកដាក់ខ្លួនប្រាណក្មេងនោះ ក្នុងក្តីសង្ឃឹមថាធ្វើយ៉ាងនេះ ក្មេងនិងបានជាសះស្បើយពីជំងឺពុំរ៉ែរបស់វា ហើយវានឹងមានសុខភាពល្អ មានកម្លាំងពលំ មានប្រាជ្ញាស្មារតីល្អឡើងវិញ ។

សូមជំរាបអស់លោកអ្នកអានថា អ្វីដែលខ្ញុំបានសរសេររៀបរាប់អំពីជំនឿផ្សេង ៗ ដូចពោលខាងលើនេះ គឺជាជំនឿ ជាការចំណាំ ជាប្រផ្នូលរបស់ខ្មែរនៅក្នុងស្រុកគិរីវង្ស ខេត្តតាកែវ ។ ខ្ញុំបានសាកសួរចាស់ព្រឹទ្ធាចារ្យក្នុងភូមិជាច្រើននៃឃុំតាអូរ ឃុំព្រៃអំពក ឃុំព្រៃរំដេង ឃុំព្រះបាទជាន់ជុំ អំពីការកំណត់ចំណាំផ្សេង ៗ រួមជាមួយនឹងបទពិសោធន៍ ការសង្កេតផ្ទាល់ខ្លួនខ្លះ ៗ ។ ចំពោះជំនឿផ្សេង ៗ ទៀត ដូចជាអំពិលអំពែកចូលផ្ទះ ក្រៀលហើរខ្ពស់យំលើអាកាស ប្រហែលជាមានប្រជាជននៅខេត្តកំពង់ធំខ្លះជឿដូចនៅខេត្តតាកែវដែរ ។ ជំនឿបុរមបុរាណ មិនមែនមានដូចគ្នាសុទ្ធសាធដូចគេចាក់ពុម្ពនោះទេ ប៉ុន្តែ វាអាចខុសប្លែកគ្នាទៅតាមតំបន់ទៅតាមស្រុកខេត្ត ។ ដូច្នេះ ប្រសិនបើអស់លោកអ្នកអាននៅតំបន់ផ្សេង ចេះដឹងអ្វីអំពីជំនឿប្រពៃណីខុសប្លែកពីនេះ សូមមេត្តាសរសេរផ្ញើទៅពុទ្ធសាសនបណ្ឌិត្យដើម្បីស្រាវជ្រាវពិនិត្យផ្ទៀងផ្ទាត់ និងចងក្រងរក្សាទុកជាឯកសារឲ្យបានច្រើនសំរាប់ឲ្យកូនចៅយើង ជំនាន់ក្រោយ ៗ សិក្សាស្រាវជ្រាវជាបន្ត ។

ដោយ **មៀច ប៉ុណ្ណ**